01101968

លេខ: D86/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

| ឯកសារដើម |
|---|
| ORIGINAL DOCUMENT/DOCUMENT ORIGINAL |
| ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04 / 06 / 2015 |
| ម៉ោង (Time/Heure) : 13:30 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA |

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី០២ ខែ មិថុនា ឆ្នាំ ២០១៥**

ភាសា ៖ **ខ្មែរ/អង់គ្លេស**

ចំណាត់ថ្នាក់ឯកសារ ៖ **សាធារណៈ**

---

**សាធារណៈ(ដោយកោសលុប)**

**ការលើកលែងការចោទប្រកាន់ប្រឆាំង ស៊ូ មេត**

---

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**
អាង ឧត្តម
Michael KARNAVAS

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គីមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

បានឃើញ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញា ដាក់នៅ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ")[1]។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពី ទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ដាក់នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម")[2]។

បានឃើញ កិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពានក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុង ហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ជាបទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា ៣(ថ្មី), ៥, ៦, ២៩ និង ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា៥០០, ៥០១, ៥០៣, ៥០៥, ៥០៦, ៥០៧ និង៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

បានឃើញ វិធាន ២៣ស្ទួន និង៥៥ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង")។

បានឃើញ មាត្រា ៧.១ និង ២៤៧(ថ្មី)នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

បានឃើញ សេចក្តីចម្លងសំបុត្រមរណភាពលេខ២៧ ធ្វើនៅសង្កាត់រតនៈ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣[3] ។

---

[1]សំណុំរឿង ០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។ សំណុំរឿង ០០៣ ឯកសារ D1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ។

[2]សំណុំរឿង ០០៣ ឯកសារ D120 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

[3] សំណុំរឿងលេខ០០៣, D86/1/1, លិខិតមរណៈភាពលេខ៩១៨/១៣ ម.ព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣ របស់មន្ទីរពេទ្យយោធភូមិភាគទី៥ ។ សេចក្តីចម្លងសំបុត្រមរណភាពលេខ២៧ ធ្វើនៅសង្កាត់រតនៈ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ។ លិខិតបញ្ជាក់មរណៈភាព លេខ២១៦/១៣ ម.ព ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣ របស់មន្ទីរពេទ្យយោធភូមិភាគទី៥ ។

បានឃើញ *ការជូនដំណឹងអំពីការស្លាប់របស់ជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង ០០៣* ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣[4]។

## ប្រវត្តិនីតិវិធីពាក់ព័ន្ធ

១. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅការិយាល័យសហចៅក្រមស៊ើបអង្កេត("ក.ស.ច.ស") ដោយចោទថា ស៊ូ ម៉េត ដែលគេស្គាល់ផងដែរថាមានឈ្មោះ ស៊ូ សាម៉េត[5] បានប្រព្រឹត្ត(ដោយផ្ទាល់ខ្លួន ឬ តាមរយៈការចូលរួមសហឧក្រិដ្ឋកម្មរួម) រៀបចំផែនការ ញុះញង់ បញ្ជា និងជួយនិងជំរុញឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពានបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[6]។ ស៊ូ ម៉េត ក៏ត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មទាំងនេះតាមរយៈការទទួលខុសត្រូវថ្នាក់លើ[7]។ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានបញ្ជាក់ថែមទៀតថា ស៊ូ ម៉េត គឺជាមេដឹកនាំជាន់ខ្ពស់ម្នាក់ និង/ឬជាជនម្នាក់ដែលទទួលខុសត្រូវខ្ពស់បំផុត

---

[4]សំណុំរឿង ០០៣ ឯកសារ D86 *ការជូនដំណឹងអំពីការស្លាប់របស់ជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង ០០៣* ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣។

[5]ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៩៦-១០២។ *សូមមើលផងដែរ* ឯកសារD4.1.601 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ទី១ ទំព័រ ៣ និង ១១ ឯកសារD4.1.854 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ទី២ ទំព័រ ២-៣ និង៥-៦ ឯកសារD4.1.845 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ទី២ ទំព័រ ៥-៦ និង ៨ ឯកសារD4.1.503 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ទំព័រ៤ ឯកសារD4.1.837 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ទំព័រ៣ និង ៥-៦ ឯកសារD1.3.33.13 កំណត់ហេតុនៃការសួរចម្លើយ [redacted] ទំព័រ៦ ឯកសារD4.1.1107 កំណត់ហេតុនៃការសួរចម្លើយ [redacted] ទី១២ ទំព័រ៧ និងឯកសារD4.1.780 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១០ ទំព័រ៣-៥។

[6]ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៩៦, ៩៧ និង ៩៩។

[7]ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៩៨។

01101971



ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ យ៉ាងហោចណាស់ចាប់តាំងពីខែ មិថុនា ឆ្នាំ ១៩៧៥[8]។

២. បើយោងតាមសហព្រះរាជអាជ្ញាអន្តរជាតិស្តីទី នៅពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ស៊ូ ម៉េត បានកាន់តំណែងជាមេបញ្ជាការកងយោធពលខេមរភូមិន្ទប្រចាំយោធភូមិភាគទី ៥ និងជាទីប្រឹក្សាអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ[9]។ តំណែងរបស់ ស៊ូ ម៉េត ជាមេបញ្ជាការកងយោធពលខេមរភូមិន្ទប្រចាំយោធភូមិភាគទី ៥ ត្រូវបានបញ្ជាក់ដោយសាក្សីមួយចំនួនដែល ក.ស.ច.ស បានស្តាប់ចម្លើយ[10]។

៣. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") យូ ប៊ុនឡេង និង Siegfried Blunk បានជូនដំណឹងសហព្រះរាជអាជ្ញាអំពីការបញ្ចប់កិច្ចស៊ើបសួរ ដោយអនុលោមតាមវិធានផ្ទៃក្នុង ៦៦ ("សេចក្តីជូនដំណឹងតាមវិធាន ៦៦")[11]។

៤. នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី ទៅ ស.ច.ស ("សំណើសុំបំពេញកិច្ចស៊ើបសួរ")[12]។

---

[8]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៩៦។

[9]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៦៨។

[10]សំណុំរឿង ០០៣ ឯកសារD4.1.1053 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ទំព័រ ៣។ សំណុំរឿង ០០៣ ឯកសារD4.1.508 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ទំព័រ៦។ សំណុំរឿង ០០៣ ឯកសារD4.1.503 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ទំព័រ៤។ សំណុំរឿង ឯកសារD4.1.513 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ទំព័រ២ សំណុំរឿង ០០៣ ឯកសារD4.1.1107 កំណត់ហេតុនៃការសួរចម្លើយ [redacted] ទំព័រ៧។ *សូមមើលផងដែរ* សំណុំរឿង ០០៣ ឯកសារD3/2.1.10 [redacted] ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១១។

[11]សំណុំរឿង ០០៣ ឯកសារ D13 *សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ* ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។

[12]សំណុំរឿង ០០៣ ឯកសារ D17 *សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿងលេខ ០០៣ សុំឲ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ* ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១។ សំណុំរឿង ០០៣ ឯកសារ D18 *សំណើសុំលើកទី២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក ស៊ូ ម៉េត ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស* ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១១។ សំណុំរឿង ០០៣ ឯកសារ D19 *សំណើបំពេញកិច្ចស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញាអន្តរជាតិអន្តរជាតិទាក់ទងនឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ* ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១១។

ស.ព.អ ក៏បានដាក់សេចក្តីអង្កេតអំពីស្ថានភាពនៃកិច្ចស៊ើបសួរ ដោយបញ្ជាក់ថា វិធានផ្ទៃក្នុង ៥៥(២)ដាក់លក្ខខណ្ឌតម្រូវឲ្យធ្វើការស៊ើបអង្កេតយ៉ាងពេញលេញ ទៅលើការចោទប្រកាន់នានាដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយការស៊ើបអង្កេតសំណុំរឿង ០០៣ មិនអាចត្រូវបានចាត់ទុកថាបានចប់សព្វគ្រប់ទេ[13]។

៥. នៅថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១១ ស.ច.ស បានបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ពីព្រោះថា សំណើទាំងនេះត្រូវបានដាក់ដោយ ស.ព.អ តែម្នាក់ឯងដោយគ្មានកំណត់ហេតុនៃករណីខ្វែងយោបល់គ្នាជាមុនជាមួយសហព្រះរាជអាជ្ញាជាតិ ហើយសហព្រះរាជអាជ្ញាជាតិមិនបានផ្ទេរសិទ្ធិអំណាចឲ្យ ស.ព.អ ដាក់សំណើសុំបំពេញកិច្ចស៊ើបសួរទេ (“ដីកាសម្រេចថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១១”)[14]។

៦. នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ បន្ទាប់ពីបានចុះហត្ថលេខាលើករណីខ្វែងយោបល់គ្នាជាមួយសហព្រះរាជអាជ្ញាជាតិរួចមក ស.ព.អ បានដាក់សាឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី (“សំណើដាក់ឡើងវិញ”)[15]។

៧. នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ស.ព.អ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១១ (“បណ្តឹងឧទ្ធរណ៍ទីមួយរបស់ ស.ព.អ”)[16]។

---

[13]សំណុំរឿង ០០៣ ឯកសារ D17 *សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿងលេខ ០០៣ សុំឲ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ* ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១១ កថាខណ្ឌ ៣ និង ៥។

[14]សំណុំរឿង ០០៣ ឯកសារ D20/3 *ដីកាសម្រេចស្តីអំពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង ០០៣* ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១១។

[15]សំណុំរឿង ០០៣ ឯកសារ D22 *សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿងលេខ ០០៣ សុំឲ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១។ សំណុំរឿង ០០៣ ឯកសារ D23 *សំណើសុំលើកទី២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក ស៊ូ ម៉េត ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១។ សំណុំរឿង ០០៣ ឯកសារ D24 *សំណើបំពេញកិច្ចស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញាអន្តរជាតិអន្តរជាតិទាក់ទងនឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១។

៨. នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ ស.ច.ស បានបដិសេធសំណើដាក់ឡើងវិញ ជាពិសេសដោយផ្អែកលើមូលដ្ឋានចំនួនបី។ ទីមួយ ស.ច.ស យល់ឃើញថា អង្គបុរេជំនុំជម្រះ("អ.ប.ជ") បានទទួលពិនិត្យបញ្ហានេះរួចហើយបន្ទាប់ពី ស.ព.អ បានដាក់បណ្តឹងឧទ្ធរណ៍[17]។ ទីពីរ ស.ច.ស យល់ឃើញថា សំណើដាក់ឡើងវិញ បានដាក់មិនទាន់ពេលវេលា[18]។ ទីបី ស.ច.ស យល់ឃើញថា វាមិនមានភាពច្បាស់លាស់ថា ស.ព.អ បានពិចារណាល្អិតល្អន់គ្រប់គ្រាន់ថាតើជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ ត្រូវតាមលក្ខខណ្ឌតម្រូវយុត្តិធិការរបស់ អ.វ.ត.ក ឬអត់។ ស.ច.ស បានបញ្ជាក់ថា វិធាន ៥៥(១) គ្រាន់តែអនុញ្ញាតឲ្យ ស.ច.ស បំពេញកិច្ចស៊ើបសួរ *"ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"* តែប៉ុណ្ណោះ។ ដូច្នេះ កិច្ចស៊ើបសួរថាតើជនសង្ស័យត្រូវតាមលក្ខខណ្ឌតម្រូវយុត្តាធិការរបស់អ.វ.ត.ក ដែលបានកំណត់នៅក្នុងមាត្រា២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬអត់នោះ គួរតែយកជាអាទិភាពជាងកិច្ចស៊ើបសួរលើបញ្ហាផ្សេងទៀត ដើម្បីចៀសវាងកុំឲ្យប្រើប្រាស់ធនធានរបស់ អ.វ.ត.ក ក្នុងលក្ខណៈមិនចាំបាច់ និងមិនទទួលខុសត្រូវ ("ដីកាសម្រេចថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១")[19]។

៩. នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១១ ស.ព.អ បានប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ ("បណ្តឹងឧទ្ធរណ៍ទីពីររបស់ ស.ព.អ")[20]។

១០. នៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk បានលាលែងពីតំណែង[21]។

---

[16]សំណុំរឿង ០០៣ ឯកសារ D20/4/1 *បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់នឹង "ដីកាសម្រេចស្តីអំពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង ០០៣"* ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១។

[17]សំណុំរឿង ០០៣ ឯកសារ D26 *ដីកាសម្រេចស្តីអំពីការដាក់សាជាថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសំណុំរឿង ០០៣* ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ៥។

[18]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៦ ក) និង ខ)។

[19]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៦ គ) និង ឃ)។

[20]សំណុំរឿង ០០៣ ឯកសារ D26/1/1 *បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹង "សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹង០០៣"* ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១១។

១១. អ.ប.ជ បានចេញសេចក្តីអង្កេតលើបណ្តឹងឧទ្ធរណ៍ទីមួយរបស់ ស.ព.អ នៅថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១ និងលើបណ្តឹងឧទ្ធរណ៍ទីពីរ របស់ ស.ព.អ នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១។ នៅក្នុងឱកាសទាំងពីរនេះ អ.ប.ជ បានបញ្ជាក់ថា ខ្លួនមិនអាចរកសំឡេងគាំទ្រវិជ្ជមានពីចៅក្រមយ៉ាងតិចបួននាក់ដែលចាំបាច់ដើម្បីចេញសេចក្តីសម្រេចបានទេ[22]។

១២. នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង("ស.ច.ស.អ.ប") Laurent Kasper-Ansermet បានមកដល់ អ.វ.ត.ក ដើម្បីជំនួសចៅក្រម Siegfried Blunk[23]។

១៣. នៅថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១ ស.ច.ស.អ.ប បានចេញ*ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ* ដោយពិចារណាឡើងវិញលើដីកាសម្រេចថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ ហើយប្រកាសទទួលយកសំណើសុំបំពេញកិច្ចស៊ើបសួរ[24]។

១៤. នៅថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង បានចេញសេចក្តីប្រកាសព័ត៌មានដែលក្នុងនោះគាត់បានកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មីមិនទាន់ត្រូវបានតែងតាំងជាផ្លូវការនៅឡើយទេ។ គាត់បានបន្ថែមទៀតថា នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១ គាត់បានជួប ស.ច.ស.អ.ប ហើយបានជម្រាប ស.ច.ស.អ.ប ថា អនុលោមតាម មាត្រា ៣ និង ៥(៦) នៃកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២៦ និង ២៧ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង ៧(៤) និងដើម្បីធានាឱ្យមានការអនុវត្តតាម"*ការអនុវត្តជាមួយសហចៅក្រមស៊ើបអង្កេតអន្តរជាតិមុនៗកន្លងមក*" សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

---

[21] *សូមមើល* http://www.eccc.gov.kh/en/articles/statement-international-co-investigating-judge។

[22]សំណុំរឿង ០០៣ ឯកសារ D20/4/4 *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹង "សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងសំណុំរឿង ០០៣"* ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៧។ សំណុំរឿង ០០៣ ឯកសារ D26/1/3 *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹង "សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី"* ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៦។

[23] *សូមមើល* http://www.eccc.gov.kh/en/articles/press-release-international-reserve-co-investigating-judge។

[24]សំណុំរឿង ០០៣ ឯកសារ D28 *ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ* ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ៩។

បម្រុងត្រូវតែរង់ចាំទទួលបានការតែងតាំងជាផ្លូវការជាមុនសិន មុននឹងចាប់ផ្ដើមការងាររបស់ខ្លួន។ ដោយសារមូលហេតុនេះ ទើប ចៅក្រម យូ ប៊ុនឡេង បានបញ្ជាក់ថា គាត់មិនយល់ឃើញថា កិច្ចដែលបានអនុវត្តដោយ ស.ច.ស.អ.ប មានសុពលភាពតាមផ្លូវច្បាប់ទេ[25]។

១៥. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ស.ច.ស.អ.ប បានជូនដំណឹង ស៊ូ ម៉េត ថា គាត់ជាប់ឈ្មោះជាជនសង្ស័យម្នាក់នៅក្នុងកិច្ចស៊ើបសួរ ដែលកំពុងបន្តដំណើរការអំពីការចោទប្រកាន់នានា ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[26]។ នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ស.ច.ស.អ.ប បានចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ដោយបង្គាប់ឱ្យអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បំពេញកិច្ចស៊ើបសួរសំណុំរឿង ០០៣[27]។

១៦. នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ស.ច.ស.អ.ប បានដាក់លិខិតលាលែងតំណែងរបស់គាត់ ដោយចូលជាធរមានចាប់ពីថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១២[28]។ រវាងថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ដល់ថ្ងៃលាលែងតំណែងរបស់គាត់ ស.ច.ស.អ.ប បានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន[29]។

---

[25] សូមមើល http://www.eccc.gov.kh/en/articles/statement-national-co-investigating-judge-unofficial-translation។

[26] សំណុំរឿង ០០៣ ឯកសារ D31 *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ[វិធាន ២១(១)(ឃ)]* ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២។ ស.ច.ស.អ.ប បានជូនដំណឹង ស៊ូ ម៉េត ដោយផ្ទាល់មាត់នៅថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១២ *សូមមើល* សំណុំរឿង ០០៣ ឯកសារ D34 *របាយការណ៍ស្ដីពីកិច្ចស៊ើបសួរដល់ទីកន្លែងដែលត្រូវបានធ្វើឡើងនៅថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១២ សម្រាប់សំណុំរឿង ០០៣* ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ២។

[27] សំណុំរឿង ០០៣ ឯកសារD32 *ដីកាចាត់ឱ្យស៊ើបសួរជំនួស* ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២។

[28] *សូមមើល* http://www.eccc.gov.kh/en/articles/press-release-international-reserve-co-investigating-judge។

[29] *សូមមើលឧទាហរណ៍* សំណុំរឿង ០០៣ឯកសារD37 *កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី* [redacted] ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២។ សំណុំរឿង ០០៣ ឯកសារD39 *កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី* [redacted] ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២។ សំណុំរឿង ០០៣ ឯកសារD40 *កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី* [redacted] ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២។ សំណុំរឿង ០០៣ ឯកសារD41 *កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី* [redacted] ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១២។ សំណុំរឿង ០០៣ ឯកសារD45 *កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី* [redacted] ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២។

១៧. នៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី Mark B. Harmon បានចូលធ្វើការនៅ អ.វ.ត.ក[30]។

១៨. នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ បន្ទាប់ពីបានចុះហត្ថលេខាលើករណីខ្វែងយោបល់គ្នាជាមួយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហចៅក្រមស៊ើបអង្កេតជាតិ បានដាក់ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យទៅការិយាល័យសហព្រះរាជអាជ្ញា ដើម្បីរៀបចំដីកាសន្និដ្ឋានស្ថាពរតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង[31]។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចុះហត្ថលេខាលើដីកាចាត់ឱ្យស៊ើបសួរជំនួស ដោយបង្គាប់ឱ្យអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បំពេញកិច្ចស៊ើបសួរសំណុំរឿង ០០៣[32]។

១៩. នៅថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ស.ព.អ បានឆ្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ដោយបញ្ជាក់ថា គាត់មិនចាត់ទុកថា កិច្ចស៊ើបសួរបានចប់សព្វគ្រប់ឡើយ ហើយបានស្នើសុំ ស.ច.ស ឱ្យបន្តកិច្ចស៊ើបសួរសំណុំរឿង ០០៣[33]។ គាត់បានកត់សម្គាល់ថែមទៀតថា ស.ច.ស.អន្តរជាតិ បានដាក់ដីកាចាត់ឱ្យស៊ើបសួរជំនួសចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ចូលក្នុងសំណុំរឿង០០៣។ ស.ព.អ បានពិចារណាថា ដោយបំពេញកិច្ចស៊ើបសួរផ្លូវការនេះ បន្ទាប់ពីមានសេចក្តីជូនដំណឹង តាមវិធានផ្ទៃក្នុងវិធាន៦៦រួចមក ប៉ុន្តែ មុនពេលចេញដីកាដំណោះស្រាយនោះ សេចក្តីជូនដំណឹងតាមវិធាន៦៦ បានផុតកំណត់ពេលវេលា ហើយគ្មានអានុភាពផ្នែកច្បាប់ទេ[34]។

២០. នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ស.ច.ស បានចេញសេចក្តីប្រកាសជាសាធារណៈបញ្ជាក់ពីគោលជំហររៀងៗខ្លួនទាក់ទងនឹងស្ថានភាពសំណុំរឿង ០០៣។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិគូសបញ្ជាក់ថា លោកចាត់ទុកថា កិច្ចស៊ើបសួរនៃសំណុំរឿង០០៣ នៅកំពុងបន្ត ចំណែកសហចៅក្រមស៊ើបអង្កេតជាតិបានចាត់ទុកថា ការស៊ើបសួរនៅក្នុងសំណុំរឿង ០០៣

---

[30] *សូមមើល* http://www.eccc.gov.kh/en/articles/mark-harmon-sworn-international-co-investigating-judge។

[31] សំណុំរឿង ០០៣ ឯកសារ D52 *ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ* ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[32] សំណុំរឿង ០០៣ ឯកសារ D54 *ដីកាចាត់ឱ្យស៊ើបសួរជំនួស* ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[33] សំណុំរឿង ០០៣ ឯកសារ D52/1 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣* ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៣។

[34] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤-៦។

ត្រូវបានបិទរួចហើយ ដោយសហចៅក្រមស៊ើបអង្កេតទាំងពីរ គឺសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk [35]។

២១. នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣ សំឡេងសហរដ្ឋអាមេរិក បានរាយការណ៍ថា ស៊ូ ម៉េត បានស្លាប់នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣[36]។ នៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ ស.ច.ស បានស្នើទៅសង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ឱ្យផ្តល់លិខិតបញ្ជាក់មរណភាព និងឯកសារមុនមរណភាពរបស់ស៊ូ ម៉េត។ ស.ច.ស ក៏បានស្នើទៅសង្កាត់ឱ្យទាក់ទងគ្រួសារ ឬកន្លែងការងាររបស់ស៊ូ ម៉េត ហើយស្នើពួកគាត់ឱ្យផ្តល់ឯកសារពេទ្យរបស់ស៊ូ ម៉េត ដែលពួកគាត់អាចមាន[37]។ នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ ស.ច.ស បានស្នើទូរទស្សន៍អាស៊ីអាគ្នេយ៍ ឱ្យផ្តល់ខ្សែអាត់វីដេអូអំពីពិធីបុណ្យសពរបស់ ស៊ូ ម៉េត។

២២. នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៣ ស.ច.ស បានទទួលលិខិតបញ្ជាក់មរណភាពរបស់ជនសង្ស័យ ស៊ូ ម៉េត ដែលចេញដោយមន្ទីរពេទ្យយោធភូមិភាគទី ៥ និងសេចក្តីថតចម្លង

---

[35] *សូមមើល* http://www.eccc.gov.kh/en/articles/statement-co-investigating-judges-regarding-case-003 នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣។

[36] សារព័ត៌មាន សំឡេងសហរដ្ឋអាមេរិក *ជនសង្ស័យខ្មែរក្រហមឈ្មោះ ស៊ូ ម៉េត បានស្លាប់ រាយការណ៍ពីសាក្សី* ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣ (http://www.voacambodia.com/content/khmer-rouge-suspect-sou-met-dead-witnesses-report/1690436.html)។ សារព័ត៌មាន The Associated Press *ជនសង្ស័យអំពីអំពើឃោរឃៅនៅសម័យខ្មែរក្រហមរបស់ប្រទេសកម្ពុជា* បានស្លាប់ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣។ សារព័ត៌មាន The Washington, The Associated Press អតីតមេទ័ពជើងអាកាសខ្មែរក្រហមដែលស្ថិតនៅក្រោមការស៊ើបអង្កេតអំពីអំពើឃោរឃៅនៅកម្ពុជាកាលពីទស្សវត្សរ៍ ១៩៧០ បានស្លាប់ ចេញផ្សាយថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១៣ (http://www.cambodiatribunal.org/sites/default/files/Former%20Khmer%20Rouge%20air%20force%20leader%20investigated%20in%201970s%20Cambodian%20atrocities%20dies.pdf)។ សារព័ត៌មាន ខេមបូឌា ដេលី *ស៊ូ ម៉េត ជនសង្ស័យខ្មែរក្រហមអំពីឧក្រិដ្ឋកម្មសង្គ្រាម បានស្លាប់* ចេញផ្សាយថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ ខ្ទង់ទី៥៥ លេខ៣៧។

[37] សំណុំរឿង 00៣ ឯកសារ D86/1 *សំណើសុំលិខិតបញ្ជាក់មរណភាព និងសំណុំឯកសារព្យាបាលជំងឺពាក់ព័ន្ធនឹងលោក ស៊ូ ម៉េត* ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣។

សំបុត្រមរណភាពពីចៅសង្កាត់រតនៈ[38]។ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៣ ស.ច.ស បាន ទទួលខ្សែអាត់វីដេអូអំពីពិធីបុណ្យសពរបស់លោក ស៊ូ ម៉េត។

២៣. យោងតាមលិខិតបញ្ជាក់មរណភាពបានឱ្យដឹងថា នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ វេជ្ជបណ្ឌិត យក់ ពេជ្រមុន្នី គ្រូពេទ្យនៅមន្ទីរពេទ្យយោធភូមិភាគទី ៥ បានបញ្ជាក់ថា ស៊ូ ម៉េត អាយុ ៦៧ ឆ្នាំ បានស្លាប់នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ វេលាម៉ោង ១១.១៥ ព្រឹក បណ្តាលមកពីមូលហេតុដូចបានបញ្ជាក់នៅក្នុងលិខិតបញ្ជាក់នេះ[39]។ មរណភាពរបស់ស៊ូ ម៉េត ក៏ត្រូវបានបញ្ជាក់ថែមទៀតដោយគ្រូពេទ្យដដែល និងនាយកមន្ទីរពេទ្យឈ្មោះ វេជ្ជបណ្ឌិត សុខ វណ្ណារ៉ា នៅថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ២០១៣។

២៤. នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ ដោយផ្អែកលើលិខិតបញ្ជាក់មរណភាព រួមបញ្ចូលទាំងព័ត៌មានទាក់ទងនឹងតំណែងដែលស៊ូ ម៉េត បានកាន់នៅពេលដែលគាត់ស្លាប់ និងដោយបានពិនិត្យមើលខ្សែអាត់វីដេអូអំពីពិធីបុណ្យសពរបស់ស៊ូ ម៉េត រួចមក ស.ច.ស បានជូនដំណឹងសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ ថា ស.ច.ស បានរកឃើញការពិតថា ស៊ូ ម៉េត បានស្លាប់ហើយ ហើយផលប៉ះពាល់ផ្នែកច្បាប់ដែលបណ្តាលមកពីមរណភាពរបស់គាត់ រួមបញ្ចូលទាំងការផុតរលត់បណ្តឹងអាជ្ញាប្រឆាំងគាត់នឹងត្រូវដោះស្រាយនៅក្នុងដីកាដំណោះស្រាយ[40]។ ទោះយ៉ាងណា ស.ច.ស បានពិចារណាឡើងវិញខ្លះអំពីគោលជំហររបស់ខ្លួនទាក់ទងនឹងពេលវេលាដោះស្រាយផលប៉ះពាល់ផ្នែកច្បាប់ ដែលបណ្តាលមកពីមរណភាពរបស់ស៊ូ ម៉េត ហើយ ស.ច.ស ជឿជាក់ថា ដើម្បីជាប្រយោជន៍យុត្តិធម៌គឺត្រូវផ្តល់ការបំភ្លឺមួយចំនួននៅដំណាក់កាលនេះនៃកិច្ចស៊ើបសួរ មុនពេលចេញដីកាដំណោះស្រាយ។

---

[38] សំណុំរឿងលេខ០០៣, D86/1/1, លិខិតមរណៈភាពលេខ៩១៨/១៣ ម.ព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣ របស់មន្ទីរពេទ្យយោធភូមិភាគទី៥ ។ សេចក្តីចម្លងសំបុត្រមរណភាពលេខ២៦៧ ធ្វើនៅសង្កាត់រតនៈ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ។ លិខិតបញ្ជាក់មរណៈភាព លេខ២១៦/១៣ ម.ព ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣ របស់មន្ទីរពេទ្យយោធភូមិភាគទី៥ ។

[39] សំណុំរឿងលេខ០០៣, D86/1/1, លិខិតមរណៈភាពលេខ៩១៨/១៣ ម.ព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣ របស់មន្ទីរពេទ្យយោធភូមិភាគទី៥ ។ សេចក្តីចម្លងសំបុត្រមរណភាពលេខ២៦៧ ធ្វើនៅសង្កាត់រតនៈ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ។ លិខិតបញ្ជាក់មរណៈភាព លេខ២១៦/១៣ ម.ព ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣ របស់មន្ទីរពេទ្យយោធភូមិភាគទី៥ ។

[40] សំណុំរឿង ០០៣ ឯកសារ D86 *ការជូនដំណឹងអំពីការស្លាប់របស់ជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង ០០៣* ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣។

**ពិភាក្សា**

២៥. វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក មិនមានការចែងឲ្យបានច្បាស់អំពីលទ្ធផលនានាដែលកើតឡើងបន្ទាប់ពីមរណភាពរបស់ជនសង្ស័យ ដែលជាប់ឈ្មោះនៅក្នុងកិច្ចស៊ើបសួរមុនពេលចេញដីកាដំណោះស្រាយទេ។ ខណៈដែលវិធានផ្ទៃក្នុង មិនដោះស្រាយបញ្ហាចោទណាមួយដែលកើតឡើងនៅក្នុងអំឡុងពេលបំពេញកិច្ចស៊ើបសួរក៏ដោយ ក៏បទប្បញ្ញត្តិនានានៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកអនុវត្ត[41]។

២៦. អនុលោមតាមមាត្រា ៧.១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា មរណភាពរបស់ជនសង្ស័យនាំឲ្យផុតរលត់បណ្តឹងអាជ្ញាប្រឆាំងគាត់ ស.ច.ស យល់ឃើញថា មរណភាពរបស់ ស៊ូ ម៉េត នាំឲ្យផុតរលត់បណ្តឹងអាជ្ញា និងបញ្ចប់បណ្តឹងរដ្ឋប្បវេណីប្រឆាំងគាត់នៅចំពោះមុខ អ.វ.ត.ក។

២៧. ស.ច.ស ឯកភាពថា មរណភាពរបស់ ស៊ូ ម៉េត នាំឲ្យផុតរលត់បណ្តឹងអាជ្ញា និងបញ្ចប់បណ្តឹងរដ្ឋប្បវេណីប្រឆាំងគាត់ ហេតុដូច្នេះ ការចោទប្រកាន់នានាប្រឆាំង ស៊ូ ម៉េត ត្រូវលើកលែង ទោះបីជា ស.ច.ស មានគោលជំហរផ្សេងគ្នាទាក់ទងនឹងលេខឯកសារ“D”ដែលត្រូវដាក់លើដីកាសម្រេចនេះក៏ដោយ[42]។

**តាមសំអាងហេតុខាងលើ សហចៅក្រមស៊ើបអង្កេត៖**

**ជូនដំណឹង** ភាគីនានានៅក្នុងសំណុំរឿង ០០៣ ថា មរណភាពរបស់ជនសង្ស័យ ស៊ូ ម៉េត ហៅ ស៊ូ សាម៉េត ភេទ ប្រុស កើតនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៤៨ នៅភូមិស្រែអណ្តូង ឃុំពាមរ៍ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ប្រទេសកម្ពុជា មានអានុភាពផុតរលត់បណ្តឹង

---

[41]សំណុំរឿង ០០២ ឯកសារ D55/I/8 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំរោមយភាព* ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ កថាខណ្ឌ១៤-១៥។

[42]សហចៅក្រមស៊ើបអង្កេតជាតិ យល់ឃើញថា កិច្ចស៊ើបសួរដែលបានអនុវត្ត បន្ទាប់ពីការបិទសំណុំរឿង ០០៣ មិនត្រូវបានអនុវត្តដោយមានសុពលភាពទេ ដែលនេះប៉ះពាល់ដល់លេខឯកសារសំណុំរឿងដែលគួរដាក់លើដីកាសម្រេចនេះ។ ដូច្នេះ លេខឯកសារ “D” ដែលបានដាក់លើដីកាសម្រេចនេះ មិនប៉ះពាល់ដល់គោលជំហររបស់សហចៅក្រមស៊ើបអង្កេតជាតិលើសំណុំរឿងនេះទេ។





ECCC * CETC

០០៣/០៧-០៩-២០០៩/អ.វ.ត.ក-ក.ស.ច.ស លេខ: D 86/3

អាជ្ញា និងបញ្ចប់បណ្តឹងរដ្ឋប្បវេណីប្រឆាំងគាត់នៅក្នុងសំណុំរឿង ០០៣ នៅចំពោះមុខ អ.វ.ត.ក។

**សម្រេច**លើកលែងការចោទប្រកាន់ប្រឆាំងជនសង្ស័យ ស៊ូ មេ៉ត ហៅ ស៊ូ សាមេ៉ត ដោយសារមូលហេតុបណ្តឹងអាជ្ញាផុតរលត់។

**ជូនដំណឹង**ភាគីនានាថា ការសម្រេចលើការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋដែលបានចោទនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នឹងត្រូវធ្វើឡើងនៅពេលដែលចេញដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៣ អនុលោមតាមវិធានផ្ទៃក្នុង ៦៧។

ភ្នំពេញ ថ្ងៃទី០២ ខែ មិថុនា ឆ្នាំ ២០១៥

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges

Co-juges d'instruction

**យូ ប៊ុនឡេង** **Mark B. Harmon**